# ក្រុមប្រឹក្សាឃ្លាំមើលខ្មែរ ចោទប្រកាន់ប្រមុខរដ្ឋាភិបាល រារាំងដំណើរការសាលាក្តី

***ប្រភព : សារព័ត៌មានដើមអំពិល***

*Saturday, 05 December 2009 12:40 DAP NEWS*

ក្រុមប្រឹក្សា ឃ្លាំមើលកម្ពុជា បានចោទប្រកាន់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ធ្ងន់ៗថា តែងជ្រៀតជ្រែករារាំង និងព្រមានដល់ដំណើរការដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ការថ្លែងចោទប្រកាន់របស់ក្រុមប្រឹក្សា ឃ្លាំមើលកម្ពុជាដូច្នេះ បានធ្វើឡើងតាមរយៈ សេចក្តីថ្លែងការណ៍របស់ខ្លួន ចុះកាលបរិច្ឆេទ ថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ ២០០៩ នេះ។ សេចក្តីថ្លែងការណ៍បានបញ្ជាក់ថា "លោក ហ៊ុន សែន តែងតែព្យាយាមធ្វើការរារាំងមិនឱ្យតុលាការនេះ ធ្វើការងាររបស់ខ្លួនដោយឯករាជ្យ ហើយកោះហៅអតីតមេដឹកនាំ ឬ មន្ត្រីជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីចូលខ្លួនមកផ្តល់សក្ខីកម្ម ឬកាត់ទោសលើទង្វើដែលពួកគេបានប្រព្រឹត្ត ក្នុងកំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ពីព្រោះលោក ហ៊ុន សែន សំអាងថា បើសាលាក្តីខ្មែរក្រហមធ្វើបែបនេះ វានឹងបង្កឱ្យមានការបែកបាក់ឬ សង្គ្រាមផ្ទៃក្នុងនៅកម្ពុជា"។

នៅក្នុងសប្តាហ៍នេះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយក រដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីសម្ពោធសមិទ្ធិផលខាងពុទ្ធិចក្រនៅក្នុងខេត្តកំពង់ចាម សម្តេចបានថ្លែងថា "សុខចិត្តឱ្យសាលាក្តីខ្មែរ ក្រហមនេះបរាជ័យ តែមិនឱ្យសង្គ្រាមកើតឡើងនៅលើទឹកដីកម្ពុជាម្តងទៀតឡើយ"។ ការថ្លែងព្រមានរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងសប្តាហ៍នេះ ក៏បានកម្រិតឱ្យមានការសាកសួរ និងយកមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ មកទទួលខុសត្រូវ នៅចំពោះមុខអង្គសវនាការនៃសាលាក្តីខ្មែរក្រហម ត្រឹមតែចំនួន ៥ នាក់ប៉ុណ្ណោះ។ សម្តេចបានថ្លែងថា "កាត់ប៉ុណ្ណឹងបានហើយ ដែលនេះជាចំនួនច្រើនជាងអ្វី ដែលយើងបាន គ្រោងទុកទៅទៀត"។

ដោយសារហេតុផលទាំងអស់នេះហើយ ទើបធ្វើឱ្យក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា ដែលចុះហត្ថលេខាដោយលោក អៀ ចាន់ណា អគ្គលេខាធិការ នៃក្រុមប្រឹក្សាឃ្លាំមើលកម្ពុជានេះ បានចេញសេចក្តីថ្លែងការណ៍ ដោយទាត់ចោលការអះអាងរបស់ប្រមុខរាជរដ្ឋា ភិបាលកម្ពុជា ដែលបានថ្លែងទៅកាន់ជនរួមជាតិកម្ពុជាទាំងស្រុងនោះ។ សេចក្តីថ្លែងការណ៍បានបន្តថា "គ្រប់រចនាសម្ព័ន្ធនៃកងកម្លាំងប្រដាប់អាវុធទាំងអស់ និងប្រទេសកម្ពុជា ត្រូវបានគ្រប់គ្រង និងកាន់កាប់ផ្តាច់មុខដោយលោក ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជា។ ម្យ៉ាងទៀត លោក ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជា តែងឃោសនាបោកប្រាស់ប្រជាពលរដ្ឋកម្ពុជាជាយូរយារណាស់មកហើយថា រូបលោក និងគណបក្សនេះ ជាអ្នកវាយផ្តួលរំលំរបបខ្មែរក្រហម ហើយនាំមកនូវសន្តិភាពជូនប្រជាពលរដ្ឋកម្ពុជា ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩"។

សេចក្តីថ្លែងការណ៍បានបញ្ជាក់ទៀតថា "ស្ទើរតែគ្រប់វេទិកាទាំងអស់ រូបលោកតែងតែថ្លែងយកចំណេញនយោបាយពីរបបនេះ ដោយរំលឹកឡើងវិញដដែលៗ អំពីការឈឺចាប់នានា ដែលប្រជាពលរដ្ឋកម្ពុជាបានជួបប្រទះក្នុងរបបនោះ ក្នុងគោលបំណងឱ្យប្រជាពលរដ្ឋខ្មែរ បន្តដឹងគុណរូបលោក (សម្តេច ហ៊ុន សែន) និងគណបក្សប្រជាជនកម្ពុជា"។ សេចក្តីថ្លែងការណ៍បានចោទប្រកាន់ សម្តេច ហ៊ុន សែន គឺជាអ្នកបង្កអស្ថិរភាពដល់សង្គម ពីព្រោះលោកបានព្យាយាមបំភ្លៃការពិត និងភូតភរកុហកប្រជាពលរដ្ឋខ្មែរ ជាពិសេសអតីតយោធា ឬមន្ត្រីតូចតាចក្នុងរបបខ្មែរក្រហម ដោយយកលេសថា "តុលាការខ្មែរក្រហមនឹងបង្កឱ្យមានសង្គ្រាមកើត ឡើងវិញ "។

សេចក្តីថ្លែងការណ៍នោះ ក៏បានគាំទ្រឱ្យ តុលាការខ្មែរក្រហម ដែលចេញដីកាកោះហៅមន្ត្រីជាន់ខ្ពស់នៃមន្ត្រីគណបក្សប្រជាជនកម្ពុជា ក្នុងនោះមានប្រធានព្រឹទ្ធសភា សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម, សម្តេចអគ្គមហាពញាចក្រី ហេង សំរិន, លោក ហោ ណាំហុង រដ្ឋមន្ត្រី

ក្រសួងការបរទេស, លោក គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, លោក អ៊ុក ប៊ុនឈឿន និងលោក ស៊ឹម កា សមាជិកព្រឹទ្ធសភា ឱ្យចូលខ្លួនមកផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ នៅក្នុងតុលាការកម្ពុជា ដើម្បីស្វែងរកយុត្តិធមិជូនប្រជាពលរដ្ឋកម្ពុជា។

លោក រាជ សម្បត្តិ មន្ត្រីកិច្ចការសាធារណៈ នៃសាលាក្តីខ្មែរក្រហមបានឱ្យដឹងថា "គ្មានការលូកដៃណាមួយរបស់រដ្ឋាភិបាលចូលទៅក្នុងដំណើរការរបស់សាលាក្តីខ្មែរក្រហមនោះឡើយ ហើយសាលាក្តីខ្មែរក្រហម ក៏មិនមានការជ្រៀតជ្រែកនៃអធិបតេយ្យភាពរបស់ខ្លួន ដោយមន្ត្រីរដ្ឋាភិបាលណាមួយឡើយ"។ ទាំងដំណើរការនៃអង្គសវនាការលើអង្គសេចក្តី លើសំណុំរឿង ០០១ របស់អតីតប្រធានមន្ទីរ ស-២១ លោក កាំង ហ្កេចអ៊ាវ ហៅ ឌុច និងការឈានទៅបើកសវនាការ លើអង្គសេចក្តីនៃសំណុំរឿង ០០២ លោក រាជ សម្បត្តិ បានបញ្ជាក់ថា "តុលាការធ្វើអ្វីៗ តាមឆន្ទានុសិទ្ធិរបស់ខ្លួន មិនមានការជ្រៀតជ្រែកណាមួយឡើយ ហើយសាលាក្តីខ្មែរក្រហមនោះទៀតសោត មានខ្មែរយើង និងអន្តរជាតិសុទ្ធតែបានចូលរួមឃ្លាំមើលទាំងអស់គ្នា បើមានភាពមិនប្រក្រតីអ្វីមួយនោះ ខាងភាគីអន្តរជាតិគេអត់សុខចិត្តទេ"។

លោក ទិត្យ សុធា ក្រុមអ្នកនាពាក្យនៃអង្គភាពប្រតិកម្មរហ័ស នៃទីស្តីការគណៈរដ្ឋមន្ត្រីបានឱ្យដឹងផងដែរថា "ការថ្លែងអះអាង នៃសេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជានោះ គ្រាន់តែជាការលើកឡើងមិនសមហេតុផល និងមិនបានឆ្លុះបញ្ចាំងពីភាពពិតនៃនយោបាយរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជានោះទេ"។

អតីតមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត នៃរបបកម្ពុជាប្រជាធិបតេយ្យមួយចំនួន ត្រូវបានតុលាការកម្ពុជា នៃអតីតសាធារណរដ្ឋកម្ពុជា ធ្លាប់យកមកជំនុំជម្រះម្តងរួចមកហើយ ដែលបញ្ជាក់ពីចេតនារបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ស្រែកឃ្លានយុត្តិធមិមកផ្តល់ជូនប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ដែលបានស្លាប់បាត់បង់ជីវិតយ៉ាងខ្លោចផ្សា ក្រោមការសម្លាប់រង្គាលដ៏ឃោរឃៅរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានកាន់កាប់ប្រទេសកម្ពុជារយៈពេល ៣ ឆ្នាំ ៨ ខែ និង ២០ ថ្ងៃ។

លោក ជាម យៀប សមាជិកគណៈកម្មា ធិការអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ធ្លាប់ប្រាប់វិទ្យុ "ដើមអម្ពិល" ថា "របបកម្ពុជាប្រជាធិបតេយ្យ ក្នុងមួយជីវិតនេះ ខ្ញុំមិនអាចបំភ្លេចបានឡើយ ខ្ញុំផ្តាំកូនផ្តាំចៅ និងញាតិមិត្តរបស់ខ្ញុំ បើផឹកទឹកសូមកូនទឹកដល់ស្ទឹង ទន្លេ បឹងបួរ និងទឹកភ្លៀង ដែលបានផ្តល់ឱ្យយើង"។ លោក ជាម យៀប ដែលមានសមាជិកគ្រួសារ សាច់ញាតិ បងប្អូន ជាង ៣០ នាក់ បានស្លាប់បាត់បង់ជីវិត ក្រោមការកាប់សម្លាប់ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានថ្លែងដោយឈឺចាប់ នៅពេលដែលគេនិយាយថា ថ្ងៃទី ០៧ ខែមករា ឆ្នាំ ១៩៧៩ និងថ្ងៃទី០២ ខែធ្នូ ឆ្នាំ ១៩៧៨ នៃការបង្កើតរណសិរ្សសង្គ្រោះជាតិកម្ពុជា ជាថ្ងៃដែលកម្ពុជាធ្លាក់ ចូលទៅក្នុងការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តវៀតណាម។

លោក ជាម យៀប បានថ្លែងដោយដឹងគុណថា "នៅក្នុងសម័យនោះ ប្រជាពលរដ្ឋកម្ពុជាជាច្រើន បាននិយាយថា ឱ្យតែមាន លោកណាដែលបានមកសង្គ្រោះចេញពីគុកឥតជញ្ជាំង និងដឹងគុណអស់មួយជីវិត ឱ្យធ្វើអ្វីក៏ធ្វើតាមដែរ"។

លោក ទិត្យ សុធា បានហៅសេចក្តីថ្លែងការណ៍របស់ ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជានោះថា "ជាការលើកឡើងដោយគ្មានមូលដ្ឋានពិតប្រាកដ ចេះតែចោទប្រកាន់គេ ក្នុងគោលបំណងអ្វីមួយនៃនយោបាយរបស់ខ្លួន "។